AGING AND LONG-TERM SUPPORT ADMINISTRATION
RESIDENTIAL CARE SERVICES DIVISION

# សេចក្តីថ្លែងការណ៍ស្តីពីសិទ្ធិរបស់ទីតិជនទន់ខ្សោយ

**Vulnerable Adult Statement of Rights**

ដែលបានគ្រោងទុកសម្រាប់ការប្រើប្រាស់នៅក្នុង **CCRSS** និង **ICF/IID (RHC)**

យោងតាមច្បាប់ Chapter 74.34 RCW, អ្នកមានសិទ្ធិក្នុងការមានសេរីភាពរួចផុតពីការត្រូវគេបោះបង់, រំលោភបំពាន, កេងប្រវ័ញ្ចប្រាក់កាស, និងធ្វេសប្រហែស។ បើអ្នកមានមូលហេតុអ្វីមួយគួរឲ្យជឿថា អ្នកកំពុងជួបប្រទះនឹងការត្រូវគេបោះបង់, រំលោភបំពាន, កេងប្រវ័ញ្ចប្រាក់កាស, ឬធ្វេសប្រហែស, នោះអ្នកមានសិទ្ធិ ៖

1. រាយការណ៍ប្រាប់ទៅក្រសួងសេវាសង្គមកិច្ចនិងសុខាភិបាល (Department of Social and Health Services, DSHS) និងភ្នាក់ងារមានសមត្ថកិច្ច ព្រមទាំងចែករំលែកព័ត៌មានដែលអ្នកជឿថា អាចមានការពាក់ព័ន្ធដល់ការស៊ើបអង្កេត និងស្វែងរកជនណាម្នាក់ដែលអ្នកជឿថា អាចមានព័ត៌មានដែលពាក់ព័ន្ធករណីទាំងនោះ។
2. មានសេរីភាពរួចផុតពីការសងសឹកសម្រាប់ការផ្តល់សេចក្តីរាយការណ៍ ឬការបណ្តាលឲ្យមានសេចក្តីរាយការណ៍អំពីបទត្រូវគេ បោះបង់, រំលោភបំពាន, កេងប្រវ័ញ្ចប្រាក់កាស, ឬធ្វេសប្រហែស។
3. ទទួលបាននូវការរាប់អានដោយសេចក្តីគោរពថ្លៃថ្នូរ និងការពោលពាក្យប្រស្រ័យទាក់ទងដោយភាសាពីរោះប្រសើរ។
4. ទទួលបានការសម្របសម្រួលដោយសមរម្យសម្រាប់ពិការភាពរបស់អ្នក នៅក្នុងពេលធ្វើសេចក្តីរាយការណ៍, និងក្នុងអំឡុងពេលធ្វើ ការស៊ើបអង្កេត និងតិវិធីរដ្ឋបាល។
5. ស្នើសុំដីកា ដើម្បីហាមឃាត់ជនណាម្នាក់ ដែលបានបោះបង់, រំលោភបំពាន់, កេងប្រវ័ញ្ចប្រាក់កាស, ឬធ្វេសប្រហែសមិនថែរក្សាអ្នក ដើម្បីកុំឲ្យជនរូបនោះស្ថិតក្បែរ ឬស្នាក់នៅក្នុងបរិវេណផ្ទះសំបែងរបស់អ្នក, ធ្វើការប្រស្រ័យទាក់ទងជាមួយអ្នក, ឬប្រើប្រាក់កាស ឬទ្រព្យសម្បត្តិរបស់អ្នក។ យើងផ្តល់ជូនអ្នកនូវអង្គការណាមួយ ដែលអាចជួយអ្នក។
6. ទទួលបានព័ត៌មានពីក្រសួង DSHS និងការបញ្ជូនដោយសមរម្យទៅកាន់ទីភ្នាក់ងារដទៃៗ ដែលអាចជួយគាំពារ, ស៊ើបអង្កេត, ឬចាត់វិធានការផ្លូវច្បាប់ផ្សេងៗ។
7. ទទួលបាននូវការផ្តល់ព័ត៌មានស្តីអំពីស្ថានភាពនៃការស៊ើបអង្កេត, ការប្រតិបត្តិនីតិវិធី, ការប្រតិបត្តិចំណាត់ការតុលាការ, និងលទ្ធផលផ្សេងៗ ដែលបានធ្វើឡើងដោយទីភ្នាក់ងារដែលកាន់កាប់សំណុំរឿងណាមួយដែលពាក់ព័ន្ធនឹងរូបអ្នក ដែលត្រូវជាជនរងគ្រោះ (ក្នុងវង្វង់ក្របខ័ណ្ឌនៃល័ក្ខខ័ណ្ឌតម្រូវនានា ដែលបានត្រូវបង្កើតឡើងដោយច្បាប់)។
8. ស្នើសុំឲ្យគេបញ្ជូនទៅកាន់ទីភ្នាក់ងារគាំពារ ឬទីភ្នាក់ងារជំនួយផ្នែកច្បាប់ ដើម្បីជួយរូបអ្នកក្នុងការរៀបចំបង្កើតផែនការសុវត្ថិភាព, ផែនការស៊ើបអង្កេត, និងផែនការសវនាការ។ យើងនឹងបញ្ជូនអ្នកទៅកាន់ទីភ្នាក់ងារធនធានជំនួយសមរម្យណាមួយ។ សូមមើលលេខទូរស័ព្ទនានាដែលបានចុះជូននៅខាងក្រោម។
9. ដាក់បណ្តឹងតវ៉ាទៅក្រសួង DSHS ជាផ្លូវការឬមិនផ្លូវការ, ស្តីអំពីការស៊ើបអង្កេត ឬការធ្វើនីតិវិធី, ហើយទទួលបាននូវការឆ្លើយតបដោយសមរម្យ និងទាន់ពេលវេលា។

ដើម្បីរាយការណ៍អំពីការរំលោភបំពាន, ការបោះបង់ចោល, ការធ្វេសប្រហែស, ការធ្វេសប្រហែសដោយសាមីខ្លួន ឬការកេងប្រវ័ញ្ចប្រាក់កាស, ឬដើម្បីស្នើសុំដីកាការពារណាមួយ, សូមអញ្ជើញទូរស័ព្ទទាក់ទង ៖

បណ្តាញទូរស័ព្ទឆ្លើយតបការតវ៉ាភ្លាមៗរបស់សេវាថែទាំសុខភាពតាមគេហដ្ឋាន **(Residential Care Services Complain Hotline)**
**1-800-562-6078**
សម្លេង/ប្រព័ន្ធ **TTY** អាចទាក់ទងបានតាមលេខ **1-800-737-7931**

ដើម្បីទាក់ទងទីភ្នាក់ងារគ្រប់គ្រងសិទ្ធិពិការភាពនៃរដ្ឋវ៉ាស៊ីនតោន **(Disability Rights of Washington),** សូមអញ្ជើញទូរស័ព្ទទាក់ទង ៖

**1-800-562-2702**

ប្រព័ន្ធបញ្ជូនបន្តវ៉ាស៊ីនតោន **(TTY)** អាចរកបានតាមលេខ **711**

ដើម្បីទាក់ទងការិយាល័យបណ្តាញបណ្តឹង **Ombuds** ពិការភាពខាងការអភិវឌ្ឍ ៖

សម្លេង ៖ **(833) 727-8900**

អ្នកបកប្រែផ្ទាល់មាត់គឺអាចរកបាន

**TTY** ៖ សូមប្រើប្រព័ន្ធបញ្ជូនបន្តវ៉ាស៊ីនតោន **711**